# សិទ្ធិនៃ Medi-Cal របស់អ្នក

**សូមរក្សាទុក!**
**ព័ត៌មានដ៏មានសារៈសំខាន់ ដើម្បីជួយកុមារ និង យុវជនរហូតដល់អាយុ 21 ឆ្នាំឱ្យទទួលបានរាល់ការថែទាំងដែលពួកគេត្រូវការ**

## តើសេវាកម្មអ្វីខ្លះដែលកុមារ និងយុវជនអាចទទួលបានប្រសិនបើពួកគេស្ថិតក្នុង Medi-Cal?

ស្ថិតក្រោមច្បាប់នៃរដ្ឋ California និងច្បាប់សហព័ន្ធ រាល់កុមារ និងយុវជនទាំងអស់រហូតដល់អាយុ 21 ឆ្នាំ ដែលបានចុះឈ្មោះក្នុង Medi-Cal មានសិទ្ធិ **ពិនិត្យសុខភាព** ជាប្រចាំ និង **សេវាបង្ការ** និង **ព្យាបាល** ផ្សេងទៀតដែលចាំបាច់ដើម្បីមាន ឬទទួលបានសុខភាពល្អ។

សិទ្ធិនេះត្រូវបានគេស្គាល់នៅក្នុងច្បាប់សហព័ន្ធថាជាការពិនិត្យរាវរកជំងឺ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលឲ្យបានលឿនពីដើមទី និងម្តងម្កាល(EPSDT)។ សិទ្ធិនេះធានាថា កុមារគ្រប់រូបដែលបានចុះឈ្មោះក្នុង Medi-Cal ទទួលបានការថែទាំដែលពួកគេត្រូវការ ដើម្បីលូតលាស់ប្រកបដោយសុខភាពល្អតាមដែលអាចធ្វើទៅបាន។ នៅក្នុងរដ្ឋ California គេហៅ EPSDT ថាជា **Medi-Cal សម្រាប់កុមារ និងក្មេងជំទង់**។

សេវាកម្មទាំងនេះ **ឥតគិតថ្លៃ** លុះត្រាតែកុមារ ឬយុវជនត្រូវបានរកឃើញថាមានចំណែកនៃថ្លៃចំណាយ នៅពេលដែលពួកគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medi-Cal។

### ប្រសិនបើចាំបាច់ Medi-Cal សម្រាប់កុមារ និងក្មេងជំទង់ត្រូវតែរ៉ាប់រងសេវាកម្មទាំងនេះដោយគ្មានដែនកំណត់៖

- សេវាកម្មសុខភាពផ្លូវកាយ រួមបញ្ចូលការថែទាំបឋម និងការជួបពិនិត្យជាមួយអ្នកឯកទេស
- សេវាសុខភាពភ្នែក រួមបញ្ចូលទាំងវ៉ែនតា
- សេវាសុខភាពត្រចៀក
- សេវាពិនិត្យ និងតាមដានសុខភាពធ្មេញ
- សេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ឬគ្រឿងស្រវឹង រួមទាំងការព្យាបាល
- សេវាកម្មព្យាបាលដោយចលនា ដោយការប្រកបកិច្ចការ និងដោយសំដី
- បរិក្ខារវេជ្ជសាស្ត្រ និងសម្ភារផ្គត់ផ្គង់ ដូចជា រទេះរុញ រួមទាំងបរិក្ខារវេជ្ជសាស្ត្រប្រើបានយូរ
- ឱសថទាំងមិនតម្រូវឱ្យមានវេជ្ជបញ្ជា និងមានវេជ្ជបញ្ជា
- ការធ្វើតេស្តនៅមន្ទីរពិសោធន៍ រួមទាំងការធ្វើតេស្តឈាម ដើម្បីពិនិត្យមើលកម្រិតសំណ និងការធ្វើតេស្តរកមើលការឆ្លងមេរោគកាមរោគ (STI) និងការថែទាំតាមដានដែលចាំបាច់
- សេវាសុខភាពតាមផ្ទះ រួមទាំងការថែទាំដោយគិលានុបដ្ឋាយិកា
- ការព្យាបាលនៅមន្ទីរពេទ្យ និងនៅគេហដ្ឋាន
- សេវាសុខភាពបន្តពូជ និងផ្លូវភេទ ដូចជាការពន្យារកំណើត និងការថែទាំក្នុងពេលរំលូតកូន
- ការពិនិត្យផ្ទៃពោះ
- ការធ្វើតេស្ត និងការព្យាបាលជំងឺ COVID-19
- ការសម្របសម្រួលការថែទាំ ប្រសិនបើបានចុះឈ្មោះក្នុងគម្រោងថែទាំក្រោមការគ្រប់គ្រង
- រាល់សេវាវេជ្ជសាស្ត្រដែលចាំបាច់ផ្សេងទៀតទាំងអស់ដែលអាចត្រូវបានរ៉ាប់រងក្រោម Medi-Cal (ដែលគេស្គាល់ថាជា "សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រ") ដូចដែលបានកំណត់ដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់អ្នក។

**ប្រសិនបើអ្នកត្រូវការលិខិតនេះ ឬសម្ភា Medi-Cal ណាមួយជាទម្រង់ជំនួសដូចជា ពុម្ពអក្សរធំ ទម្រង់អូឌីយ៉ូ ស៊ីឌី ឬអក្សរស្ទាបសម្រាប់ជនពិការ ចូរទូរសព្ទទៅលេខ 1-833-284-0040។**

### កុមារ និងយុវជនមានសិទ្ធិទទួលបានការគាំទ្រដោយមិនគិតថ្លៃ ដើម្បីទទួលបានការថែទាំ ដូចជា៖

- ទទួលបានការធ្វើដំណើរដោយឥតគិតថ្លៃទៅ និងមកពីកន្លែងណាត់ជួបរបស់អ្នក ឬទៅទទួលយកឱសថ បរិក្ខារវេជ្ជសាស្ត្រ និងសម្ភារផ្គត់ផ្គង់
- គាំទ្រក្នុងការណាត់ជួបខាងវេជ្ជសាស្ត្រ
- ជួយស្វែងរកវេជ្ជបណ្ឌិត ឬអ្នកផ្តល់សេវាថែទាំសុខភាព
- សេវាបកប្រែភាសាផ្ទាល់មាត់ (អ្នកមិនគួរយកអ្នកបកប្រែផ្ទាល់មាត់ផ្ទាល់ខ្លួនរបស់អ្នកទៅជាមួយ នៅពេលណាត់ជួបផ្នែកវេជ្ជសាស្ត្រនោះទេ)

## តើ "ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ" មានន័យដូចម្តេច?

សម្រាប់កុមារ និងយុវជន **ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ** មានន័យថាជាសេវាដែលចាំបាច់ក្នុងការព្យាបាល កែតម្រូវ គ្រប់គ្រង ឬកែលម្អជំងឺ ឬស្ថានភាពសុខភាព។

វេជ្ជបណ្ឌិត ឬអ្នកផ្តល់សេវាថែទាំសុខភាពរបស់កូនអ្នក ជាធម្មតាសម្រេចចិត្តថាតើមានអ្វីមួយចាំបាច់ផ្នែកវេជ្ជសាស្ត្រដែរឬទេ។

សេវាកម្មមួយចំនួនអាចត្រូវការការអនុញ្ញាតជាមុន។ ប្រសិនបើសេវាកម្មមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រសម្រាប់កុមារ ឬយុវជនរហូតដល់អាយុ 21 ឆ្នាំ ចំនួនសេវាកម្ម ឬការព្យាបាលមិនអាចត្រូវបានកំណត់ទេ។ ជាឧទាហរណ៍ កុមារមិនអាចកំណត់ត្រឹមតែវ៉ែនតាមួយគូរៀងរាល់ពីរឆ្នាំម្តងនោះទេ។ ប្រសិនបើកុមារមានវ៉ែនតា ប៉ុន្តែមានបញ្ហាក្នុងការមើល កុមារមានសិទ្ធិទទួលបានវេជ្ជបញ្ជាថ្មី និងវ៉ែនតាថ្មីនៅពេលដែលចាំបាច់។

ប្រអប់ទី 1

### Medi-Calរបស់កូនអ្នក

កុមារ និងយុវជននៅក្នុង Medi-Cal ទទួលបានអត្ថប្រយោជន៍របស់ពួកគេតាមវិធីមួយក្នុងចំណោមវិធីទាំងពីរនេះ៖

1. **ការថែទាំក្រោមការគ្រប់គ្រង** ដោយគម្រោងធានារ៉ាប់រងសុខភាព គម្រោងសុខភាពផ្លូវចិត្ត ឬគម្រោងសុខភាពធ្មេញ **ឬ**
2. **ថ្លៃឈ្នួលតាមការប្រើប្រាស់សេវា** ដោយក្រសួងសេវាថែទាំសុខភាព (DHCS) នៃរដ្ឋ California ដែលជាទីភ្នាក់ងារ Medi-Cal របស់រដ្ឋ

ឯកសារនេះពន្យល់ពីអ្វីដែលត្រូវធ្វើប្រសិនបើកុមារ ឬយុវជនដែលបានចុះឈ្មោះមិនទទួលបានសេវាដែលចាំបាច់តាមរយៈ **ការថែទាំក្រោមការគ្រប់គ្រង** ឬ **ថ្លៃឈ្នួលតាមការប្រើប្រាស់សេវា**។ វាពន្យល់អំពីរបៀប៖

- ដាក់ពាក្យបណ្តឹងឧទ្ធរណ៍
- ស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋ
- ដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខ

សម្រាប់ជំនួយក្នុងការទទួលបានសេវា ឬសម្រាប់សំណួរអំពីអត្ថប្រយោជន៍របស់អ្នក ចូរទូរសព្ទទៅកាន់ខ្សែទូរសព្ទជំនួយពីសមាជិក Medi-Cal តាមរយៈលេខ **1-800-541-5555**។

## តើអ្នកគួរធ្វើដូចម្តេច ប្រសិនបើមានការបដិសេធ ពន្យារពេល កាត់បន្ថយ ឬបញ្ឈប់ការថែទាំកូនរបស់អ្នក?

ប្រសិនបើមានការបដិសេធ ពន្យារពេល កាត់បន្ថយ ឬបញ្ឈប់ការថែទាំកូនរបស់អ្នក ហើយអ្នកមិនយល់ស្របជាមួយនឹងការសម្រេចចិត្តដូចដែលបានរៀបរាប់នៅក្នុងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សររបស់អ្នក នោះអ្នកអាចស្នើសុំឱ្យមានការពិនិត្យឡើងវិញ និងច្រានចោលសេចក្តីសម្រេចនោះ។

នេះគឺដើម្បីគាំទ្រដល់កូនរបស់អ្នកក្នុងការទទួលបានការថែទាំដែលគេត្រូវការ និងមានសិទ្ធិទទួលបាន។ កូនរបស់អ្នកមានសិទ្ធិដាក់ពាក្យ **បណ្តឹងឧទ្ធរណ៍** ស្នើសុំ **សវនាការយុត្តិធម៌ថ្នាក់រដ្ឋ** ឬដាក់បញ្ជូន **បណ្តឹងសាទុក្ខ** ។ មិនមានការផាកពិន័យចំពោះការចាត់វិធានការណាមួយទាំងនេះទេ។

មិនថាបណ្តឹងឧទ្ធរណ៍ សវនាការយុត្តិធម៌ថ្នាក់រដ្ឋ ឬបណ្តឹងសាទុក្ខរបស់អ្នកទទួលបានជោគជ័យ ឬអត់នោះទេ ការធានារ៉ាប់រង Medi-Cal របស់កូនអ្នកនឹង **មិន** បញ្ចប់ទេ ដោយសារអ្នកបានវិធានការណាមួយទាំងនេះ។

**បណ្តឹងឧទ្ធរណ៍** តម្រូវឱ្យគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនរបស់អ្នកដើម្បីពិនិត្យមើលការបដិសេធ ការពន្យារពេល ការកាត់បន្ថយ ឬបញ្ឈប់សេវាកម្មណាមួយ ដើម្បីរកមើល ថាតើពួកគេយល់ស្របជាមួយអ្នកដែរឬអត់។

**សវនាការយុត្តិធម៌ថ្នាក់រដ្ឋ** គឺជាឱកាសមួយក្នុងការនិយាយនៅចំពោះមុខចៅក្រម ដើម្បីពិនិត្យមើលការសម្រេចចិត្តដែលគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នក ឬ DHCS (ទីភ្នាក់ងារ Medi-Cal របស់រដ្ឋ) បានធ្វើឡើង ដែលអ្នកមិនយល់ស្របជាមួយ។

**បណ្តឹងសាទុក្ខ** គឺសម្រាប់បញ្ហាណាមួយដែលអ្នកមិនពេញចិត្ត ឬមិនយល់ស្របជាមួយ ដែលបណ្តឹងឧទ្ធរណ៍ ឬសវនាការយុត្តិធម៌ថ្នាក់រដ្ឋមិនគ្របដណ្តប់។ វាគឺសម្រាប់បញ្ហា ឬក្តីកង្វល់ជាមួយនឹងគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នក ឬ DHCS ដែលមិនមែនជាការបដិសេធ ការពន្យារពេល ការកាត់បន្ថយ ឬការបញ្ឈប់សេវាកម្មនោះទេ។

អ្នកក៏អាចដាក់បណ្តឹងសារទុក្ខទៅកាន់គម្រោងគ្រប់គ្រងការថែទាំរបស់កូនអ្នកផងដែរ សម្រាប់បណ្តឹងទាក់ទងនឹងសេវាកម្មដែលមានការរ៉ាប់រងរបស់កូនអ្នក រួមទាំងគុណភាពនៃការថែទាំ ឬសិទ្ធិទទួលបានការថែទាំផងដែរ។

### របៀបដាក់បណ្តឹងឧទ្ធរណ៍ ស្នើសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋ ឬដាក់បញ្ជូនបណ្តឹងសាទុក្ខ

**អានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ។** ប្រសិនបើគម្រោងថែទាំក្រោមការគ្រប់គ្រង DHCS (ទីភ្នាក់ងារ Medi-Cal របស់រដ្ឋ) ឬអ្នកផ្តល់សេវាបដិសេធ កាត់បន្ថយ ឬបញ្ឈប់សេវាកម្មរបស់កូនអ្នក ពួកគេត្រូវតែធ្វើសេចក្តីជូនដំណឹងអំពីចំណាត់ការ ជាលាយលក្ខណ៍អក្សរ (ក៏ត្រូវបានគេហៅផងដែរថា "សេចក្តីជូនដំណឹងអំពីការកំណត់អត្ថប្រយោជន៍អវិជ្ជមាន") ជាមួយនឹងសេចក្តីសម្រេចចិត្តរបស់ពួកគេ។

អ្នកត្រូវតែទទួលបានសេចក្តីជូនដំណឹងនេះយ៉ាងហោចណាស់រយៈពេល **10** ថ្ងៃមុនពេលព្យាបាល ឬបើមិនដូច្នោះទេសេវាកម្មរបស់កូនអ្នកនឹងត្រូវបានកាត់បន្ថយ ឬបញ្ឈប់។ សេចក្តីជូនដំណឹងពន្យល់អំពី៖

- មូលហេតុ និងរបៀបដែលគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នក ឬ DHCS បានធ្វើសេចក្តីសម្រេចរបស់ខ្លួន
- សិទ្ធិរបស់អ្នក
- របៀបដាក់បណ្តឹងឧទ្ធរណ៍ ឬស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋ

**ប្រសិនបើអ្នកមិនយល់ព្រមនឹងសេចក្តីសម្រេចទេនោះ** វាជារឿងសំខាន់ក្នុងការប្តឹងឧទ្ធរណ៍ **មុនពេល** ដែលសេវាកម្មបញ្ឈប់ ឬត្រូវបានកាត់បន្ថយ ដើម្បីឱ្យពួកគេអាចបន្តក្នុងអំឡុងពេលនៃបណ្តឹងឧទ្ធរណ៍ ឬសវនាការយុត្តិធម៌ថ្នាក់រដ្ឋ។

**ប្រសិនបើអ្នក <u>មិន</u> ទទួលបានសេចក្តីជូនដំណឹងទេ** ចូរទូរសព្ទទៅលេខរបស់ សម្ពន្ធអ្នកប្រើប្រាស់សេវាសុខភាព (HCA) ដែលមាននៅទំព័រ 4។ អ្នកនៅតែអាចដាក់បណ្តឹងឧទ្ធរណ៍បាន ប្រសិនបើអ្នកមិនបានទទួលសេចក្តីជូនដំណឹង។ ដើម្បីស្វែងយល់អំពីរបៀបដាក់បណ្តឹងឧទ្ធរណ៍ ស្នើសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋ ឬដាក់បញ្ជូនបណ្តឹងសាទុក្ខ ចូរអានទំព័របន្ទាប់ទាំងនេះ។

## របៀបទទួលបានជំនួយ

### ខ្សែទូរសព្ទជំនួយពីសមាជិករបស់ Medi-Cal

ខ្សែទូរសព្ទជំនួយពីសមាជិករបស់ Medi-Cal ផ្តល់ជូនជំនួយដោយឥតគិតថ្លៃ។ ពួកគេអាចភ្ជាប់អ្នកទៅកាន់ការិយាល័យ Medi-Cal ក្នុងតំបន់របស់អ្នក គម្រោងថែទាំក្រោមការគ្រប់គ្រងរបស់អ្នក ឬទៅកាន់ធនធាន Medi-Cal ផ្សេងទៀត ដើម្បីជួយឆ្លើយសំណួររបស់អ្នកអំពី Medi-Cal។

- ទូរសព្ទ៖ 1-800-541-5555
- អនឡាញ៖ www.dhcs.ca.gov/myMedi-Cal

### សម្ព័ន្ធអ្នកប្រើប្រាស់សេវាសុខភាព (HCA)

HCA ផ្តល់ជំនួយតាមរយៈទូរសព្ទ ឬដោយផ្ទាល់ដោយឥតគិតថ្លៃដល់អ្នកចុះឈ្មោះរបស់ Medi-Cal ដើម្បីដោះស្រាយបញ្ហាសុខភាព។ ពួកគេក៏អាចភ្ជាប់អ្នកទៅកាន់ធនធានដែលឥតគិតថ្លៃ ដើម្បីជួយដោះស្រាយបញ្ហាផ្លូវច្បាប់ទាក់ទងនឹងការថែទាំសុខភាពផងដែរ។

- ទូរសព្ទ៖ 1-888-804-3536
- អនឡាញ៖ healthconsumer.org

ប្រអប់ទី 2

### ប្រសិនបើអ្នកគិតថាសេចក្តីសម្រេចមានភាពខុសឆ្គង



ប្រសិនបើអ្នកជឿជាក់ថា Medi-Cal របស់កូនអ្នកត្រូវបានបញ្ឈប់ដោយភាពខុសឆ្គង ឬកូនរបស់អ្នកត្រូវបានរកឃើញថាមិនមានសិទ្ធិទទួលបាន Medi-Cal ដោយភាពខុសឆ្គង៖

- ចូរអនុវត្តតាមការណែនាំនៅលើសេចក្តីជូនដំណឹងក្នុងការប្តឹងឧទ្ធរណ៍ **ឬ**
- ស្វែងរកទីភ្នាក់ងារសេវាមនុស្សជាតិប្រចាំខោនធីនៅក្នុងតំបន់របស់អ្នកតាមរយៈគេហទំព័រ dhcs.ca.gov/COL

# តើសិទ្ធិរបស់កូនអ្នកក្នុងការថែទាំដែលស្ថិតក្រោមគ្រប់គ្រងរបស់ Medi-Cal មានអ្វីខ្លះ?

ព័ត៌មានខាងក្រោមនៅលើទំព័រ 5-8 អនុវត្តចំពោះប្រព័ន្ធថែទាំដែលស្ថិតក្រោមការគ្រប់គ្រងទាំងអស់នៅក្នុង Medi-Cal។ កុមារភាគច្រើនដែលបានចុះឈ្មោះក្នុង Medi-Cal ទទួលបានការថែទាំរបស់ពួកគេតាមរយៈ **គម្រោងថែទាំក្រោមការគ្រប់គ្រងរបស់ Medi-Cal**។ គម្រោងនេះគឺសម្រាប់សេវាសុខភាពរាងកាយ។ គម្រោងនេះក៏សម្រាប់សេវាសុខភាពផ្លូវចិត្តមានកម្រិតដែរ ដែលគេហៅថា "សេវាសុខភាពផ្លូវចិត្តមិនឯកទេស"។

ប្រព័ន្ធថែទាំដែលស្ថិតក្រោមការគ្រប់គ្រងផ្សេងទៀតរួមមាន៖

- **សេវាសុខភាពផ្លូវចិត្តឯកទេស** សម្រាប់សេវាសុខភាពអាកប្បកិរិយាដែលពឹងផ្អែកខ្លាំង តាមរយៈគម្រោងសុខភាពផ្លូវចិត្តដាច់ដោយឡែក។
- **ប្រព័ន្ធចែកចាយឱសថដែលរៀបចំដោយ Medi-Cal** សម្រាប់ការព្យាបាលការញៀនគ្រឿងញៀន និងគ្រឿងស្រវឹង។
- **ការថែទាំសុខភាពធ្មេញស្ថិតក្រោមការគ្រប់គ្រង** សម្រាប់ការថែទាំសុខភាពធ្មេញនៅក្នុងខោនធី Los Angeles និងខោនធីSacramento។ អាន **តារាងទី 1** នៅទំព័រទី 8។

ប្រសិនបើកូនរបស់អ្នកមានបញ្ហាក្នុងការទទួលបាន ឬការបន្តសេវាកម្មដែលអ្នកគិតថាគម្រោងណាមួយខាងលើគួរតែរ៉ាប់រង ចូរអានចំណុចខាងក្រោម។ ប្រសិនបើកូនរបស់អ្នកមិនស្ថិតនៅក្នុងគម្រោង ចូរអានអំពី **ថ្លៃសេវាកម្ម** នៅទំព័រទី 9។

## តើអ្នកអាចធ្វើអ្វីបានប្រសិនបើមានការបដិសេធ ពន្យារពេល កាត់បន្ថយ ឬបញ្ឈប់ការថែទាំកូនរបស់អ្នកនៅក្នុងការថែទាំដែលស្ថិតក្រោមការគ្រប់គ្រង?

### ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាមួយគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នក។

អ្នកត្រូវតែចាប់ផ្តើមតាមរយៈការដាក់ពាក្យ **បណ្តឹងឧទ្ធរណ៍** ជាមួយគម្រោងថែទាំក្រោមការគ្រប់គ្រង។ ដើម្បីស្វែងរកគម្រោងរបស់អ្នក សូមចលទៅកាន់គេហទំព័រ www.dhcs.ca.gov/mmchpd។ បណ្តឹងឧទ្ធរណ៍តម្រូវឱ្យគម្រោងរបស់កូនអ្នកត្រួតពិនិត្យការបដិសេធ ការពន្យាពេល ការកាត់បន្ថយ ឬការបញ្ឈប់សេវាកម្មណាមួយដើម្បីស្វែងយល់ថាតើពួកគេយល់ព្រមជាមួយអ្នកឬអត់។ អ្នកត្រូវតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍មុនពេលអ្នកអាចសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋ។

- បន្ទាប់ពីកូនរបស់អ្នកទទួលបានសេចក្តីជូនដំណឹងអំពីចំណាត់ការជាលាយលក្ខណ៍អក្សរពីគម្រោងថែទាំដែលបានស្ថិតក្រោមការគ្រប់គ្រងរបស់គេរួចហើយ អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បាន។ អ្នកក៏អាចដាក់បណ្តឹងឧទ្ធរណ៍ផងដែរ ប្រសិនបើអ្នក **មិន** ទទួលបានសេចក្តីជូនដំណឹងអំពីចំណាត់ការ។
- អ្នកមានរយៈពេល **60** ថ្ងៃតាមប្រតិទិន បន្ទាប់ពីអ្នកទទួលបានសេចក្តីជូនដំណឹងអំពីចំណាត់ការ ដើម្បីដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាមួយគម្រោងថែទាំក្រោមការគ្រប់គ្រង។ អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាមួយគម្រោងជាលាយលក្ខណ៍អក្សរបាន តាមទូរសព្ទ ឬតាមអនឡាញ។ អ្នកអាចស្វែងរកលេខទំនាក់ទំនងបាននៅក្នុង **តារាងទី 1** នៅទំព័រទី 8។

ប្រអប់ទី 3

### របៀបស្នើសុំ ការបន្តនៃអត្ថប្រយោជន៍ នៅក្នុងការថែទាំក្រោមការគ្រប់គ្រង

ប្រសិនបើការជូនដំណឹងនេះនិយាយថាសេវាដែលកូនរបស់អ្នកទទួលបានរួចហើយនឹងបញ្ឈប់ ឬត្រូវបានកាត់បន្ថយ អ្នកអាចស្នើសុំ **ការបន្តនៃអត្ថប្រយោជន៍** (ក៏ហៅផងដែរថា "ការរង់ចាំជំនួយដែលបានបង់") សម្រាប់កូនរបស់អ្នកក្នុងអំឡុងពេលនៃបណ្តឹងឧទ្ធរណ៍ ឬសវនាការយុត្តិធម៌ថ្នាក់រដ្ឋ។

- អ្នកត្រូវតែប្តឹងឧទ្ធរណ៍ ឬស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋ **មុនពេល** សេវាកម្មបញ្ឈប់ ឬត្រូវបានកាត់បន្ថយ។
- គម្រោងថែទាំក្រោមការគ្រប់គ្រងត្រូវតែផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកយ៉ាងហោចណាស់រយៈពេល **10** ថ្ងៃតាមប្រតិទិន មុនពេលពួកគេមានគម្រោងបញ្ឈប់ ឬកាត់បន្ថយសេវាកម្មសម្រាប់កូនរបស់អ្នក។

ប្រអប់ទី 4

**បណ្ដឹងឧទ្ធរណ៍ ឬសវនាការយុត្តិធម៌ថ្នាក់រដ្ឋរហ័ស (លឿនជាងនេះ)**

ប្រសិនបើកូនរបស់អ្នកត្រូវការបណ្ដឹងឧទ្ធរណ៍ ឬសវនាការយុត្តិធម៌ថ្នាក់រដ្ឋ **រហ័ស** (លឿនជាងនេះ) ព្រោះតែអាយុជីវិត សុខភាព ឬសមត្ថភាពដំណើរការរបស់កូនអ្នកស្ថិតក្នុងគ្រោះថ្នាក់ ចូរទូរសព្ទទៅលេខ **1-800-743-8525** ។

អ្នកអាចអានបន្ថែមនៅក្នុងសៀវភៅណែនាំសមាជិករបស់អ្នកអំពីរបៀបក្នុងការស្នើសុំដំណើរការរហ័ស។

- ប្រសិនបើសេចក្តីជូនដំណឹងអំពីចំណាត់ការនិយាយថា សេវាកម្មដែលកូនរបស់អ្នកទទួលបានរួចហើយនឹងបញ្ឈប់ ឬត្រូវបានកាត់បន្ថយ អ្នកក៏អាចស្នើសុំឱ្យកូនរបស់អ្នកបន្តទទួលបានសេវាកម្មក្នុងអំឡុងពេលនៃបណ្តឹងឧទ្ធរណ៍ផងដែរ។ នេះត្រូវបានគេហៅថា **ការបន្តនៃអត្ថប្រយោជន៍**។ ដើម្បីស្វែងយល់អំពីរបៀបក្នុងការស្នើសុំអត្ថប្រយោជន៍នេះ ចូរអាន **ប្រអប់ទី 3** នៅលើទំព័រនេះ។
- គម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នកត្រូវតែទទួលស្គាល់បណ្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល **5**ថ្ងៃតាមប្រតិទិន គិតចាប់ពីថ្ងៃដែលពួកគេទទួលបានពាក្យបណ្តឹងឧទ្ធរណ៍។ គម្រោងនេះក៏ត្រូវតែប្រាប់អ្នកពីឈ្មោះ លេខទូរសព្ទ និងអាសយដ្ឋានរបស់បុគ្គលនៅក្នុងគម្រោងដែលអាចប្រាប់អ្នកបន្ថែមអំពីបណ្តឹងឧទ្ធរណ៍ និងស្ថានភាពនៃបណ្តឹងផងដែរ។ គម្រោងនេះត្រូវតែធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរជូនអ្នកក្នុងរយៈពេល **30** ថ្ងៃតាមប្រតិទិននៃការស្នើសុំបណ្តឹងឧទ្ធរណ៍។ នេះត្រូវបានគេហៅថាសេចក្តីជូនដំណឹងអំពីដំណោះស្រាយ។
- ប្រសិនបើស្ថានភាពរបស់កូនអ្នកមានភាពបន្ទាន់ ហើយការរង់ចាំរយៈពេល 30 ថ្ងៃនឹងធ្វើឱ្យស្ថានភាពរបស់គេកាន់តែធ្ងន់ធ្ងរ អ្នកអាចស្នើសុំសេចក្តីសម្រេច **រហ័ស** (លឿនជាងនេះ)។ សម្រាប់របៀបនៃការស្នើសុំនេះ ចូរអាន **ប្រអប់ទី 4** នៅលើទំព័រនេះ។
- អ្នកអាចទាក់ទងទៅគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នកជាមួយនឹងសំណួរអំពីការប្តឹងឧទ្ធរណ៍របស់កូនអ្នកនៅពេលណាក៏បាន។ សម្រាប់លេខទំនាក់ទំនង ចូរអាន **តារាងទី 1** នៅទំព័រទី 8។
- គម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នកអាចរួមបញ្ចូលដំណើរការដែលគេហៅថា ក្រុមប្រឹក្សាត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រឯករាជ្យ។ សេចក្តីជូនដំណឹងអំពីចំណាត់ការរបស់កូនអ្នកនឹងពន្យល់ពីដំណើរការនេះ។ ប្រសិនបើគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នកផ្តល់នូវដំណើរការនេះ វានឹងកើតឡើងបន្ទាប់ពីអ្នកបញ្ចប់ការប្តឹងឧទ្ធរណ៍របស់កូនអ្នក។ ដើម្បីស្វែងយល់បន្ថែមអំពីក្រុមប្រឹក្សាត្រួតផ្នែកវេជ្ជសាស្ត្រឯករាជ្យ ចូរទូរសព្ទទៅក្រសួងថែទាំសុខភាពក្រោមការគ្រប់គ្រងរបស់រដ្ឋ California តាមរយៈលេខ 1-888-466-2219 (TDD 1-877-688-9891)។ ឬចូលទៅកាន់គេហទំព័រ https://bit.ly/IMRCR។

## ស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋរបស់ Medi-Cal

ប្រសិនបើដំណើរការនៃបណ្តឹងឧទ្ធរណ៍របស់គម្រោងថែទាំក្រោមការគ្រប់គ្រងត្រូវបានបញ្ចប់ ហើយអ្នកនៅតែមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គម្រោង នោះអ្នកអាចស្នើសុំ ***សវនាការយុត្តិធម៌ថ្នាក់រដ្ឋ*** សម្រាប់កូនរបស់អ្នក។ អ្នកក៏អាចស្នើសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋ ប្រសិនបើគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នកមិនផ្ញើសេចក្តីជូនដំណឹងអំពីសិទ្ធិរបស់កូនអ្នកក្នុងការប្តឹងឧទ្ធរណ៍ ឬមិនផ្ញើសេចក្តីជូនដំណឹងនេះក្នុងពេលវេលាមួយដ៏សមស្រប។

សវនាការយុត្តិធម៌ថ្នាក់រដ្ឋគឺជាឱកាសមួយក្នុងការនិយាយនៅចំពោះមុខចៅក្រមដើម្បីពិនិត្យមើលសេចក្តីសម្រេចរបស់គម្រោងថែទាំក្រោមគ្រប់គ្រងដែលអ្នកមិនយល់ស្រប។ ចៅក្រមដែលធ្វើការឱ្យក្រសួងសេវាសង្គមកិច្ចនៃរដ្ឋ California មិនមែនសម្រាប់គម្រោងរបស់កូនអ្នកទេ។

- អ្នកត្រូវតែស្នើសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋក្នុងរយៈពេល **120** ថ្ងៃតាមប្រតិទិននៃកាលបរិច្ឆេទដែលអ្នកទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់គម្រោងថែទាំក្រោមការគ្រប់គ្រងលើបណ្តឹងឧទ្ធរណ៍របស់កូនអ្នក។ ចៅក្រមដែលមិនលំអៀងនឹងពិនិត្យលើករណីរបស់កូនអ្នក។ ប្រសិនបើសេចក្តីសម្រេចដែលអ្នកបានស្នើសុំសវនាការបញ្ឈប់សេវាកម្មដែលកូនរបស់អ្នកទទួលបានរួចហើយ អ្នកក៏អាចស្នើសុំការបន្តនៃអត្ថប្រយោជន៍សម្រាប់កូនរបស់អ្នកផងដែរ។ ចូរអាន **ប្រអប់ទី 3** នៅទំព័រទី 5។
- អ្នកអាចស្នើសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋបានតាមរយៈទូរសព្ទ សំបុត្រ ទូរសារ ឬតាមអនឡាញ។ ទូរសព្ទទៅលេខ 1-800-743-8525។ ឬចូលទៅកាន់គេហទំព័រ www.cdss.ca.gov/hearing-requests។

- អ្នកមានសិទ្ធិនាំមនុស្សម្នាក់មកតំណាងអ្នកនៅក្នុងសវនាការយុត្តិធម៌ថ្នាក់រដ្ឋរបស់កូនអ្នក។ អ្នកអាចនាំមិត្តភក្តិ សាច់ញាតិ មេធាវី ឬនរណាម្នាក់ដែលអ្នកជ្រើសរើស។ ដើម្បីស្វែងយល់អំពីរបៀបទទួលបានជំនួយផ្លូវច្បាប់ដោយឥតគិតថ្លៃ ចូរអាន **របៀបទទួលបានជំនួយ** នៅទំព័រទី 4។
- អ្នកមិនចាំបាច់បង់ប្រាក់សម្រាប់សវនាការយុត្តិធម៌ថ្នាក់រដ្ឋទេ។ សវនាការយុត្តិធម៌ថ្នាក់រដ្ឋគឺឥតគិតថ្លៃ។
- រដ្ឋមានរយៈពេល **90** ថ្ងៃតាមប្រតិទិនបន្ទាប់ពីកាលបរិច្ឆេទនៃការស្នើសុំឱ្យមានសវនាការយុត្តិធម៌ ថ្នាក់រដ្ឋរបស់កូនអ្នក ដើម្បីធ្វើសេចក្តីសម្រេចចុងក្រោយ។ ប្រសិនបើកូនរបស់អ្នកត្រូវការសេវាកម្មភ្លាមៗ ហើយការរង់ចាំរយៈពេល 90 ថ្ងៃនឹងធ្វើឱ្យស្ថានភាពរបស់គេកាន់តែអាក្រក់ទៅ អ្នកអាចស្នើសុំសេចក្តីសម្រេច **រហ័ស** (លឿនជាងនេះ)។ ចូរអាន **ប្រអប់ទី 4** នៅលើទំព័រទី 6។
- សម្រាប់ជំនួយបន្ថែម ចូរអានសេចក្តីជូនដំណឹងពីគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នក។ ឬ ទូរសព្ទទៅលេខ 1-800-743-8525។ ឬ ចូលទៅកាន់គេហទំព័រ www.dhcs.ca.gov/fair-hearing។

### ទាក់ទងទៅ Ombudsman

**Ombudsman** គឺជាបុគ្គលដែលធ្វើការឱ្យ DHCS (ភ្នាក់ងារ Medi-Cal របស់រដ្ឋ)។ ការងាររបស់ Ombudsman គឺជួយអ្នក និងកូនរបស់អ្នកព្យាយាមដោះស្រាយភាពមិនយល់ស្របគ្នាជាមួយគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នក។ អ្នកអាចទូរសព្ទទៅកាន់ Ombudsman នៅពេលណាក៏បាន។ នេះរាប់បញ្ចូលទាំងពេលដែលកូនរបស់អ្នកបានទទួលសេចក្តីជូនដំណឹង ប្តឹងឧទ្ធរណ៍ ស្នើសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋ ឬបានដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខ។ Ombudsman គឺសម្រាប់តែអ្នកដែលបានចុះឈ្មោះនៅក្នុងគម្រោងថែទាំងក្រោមការគ្រប់គ្រងប៉ុណ្ណោះ។

អ្នកអាចទាក់ទងទៅ Ombudsman តាមរយៈ៖

- ទូរសព្ទ៖ 1-888-452-8609
- អ៊ីមែល៖ MMCDOmbudsmanOffice@dhcs.ca.gov
  - » កុំទុកព័ត៌មានសុខភាពផ្ទាល់ខ្លួននៅក្នុងអ៊ីមែល។

ដើម្បីស្វែងយល់បន្ថែមទៀតអំពី Ombudsman សូមចូលទៅកាន់គេហទំព័រ www.dhcs.ca.gov/ombudsman។

## ចុះប្រសិនបើអ្នកមិនសប្បាយចិត្តនឹងការថែទាំរបស់កូនអ្នក វេជ្ជបណ្ឌិត ឬអ្នកផ្តល់សេវាថែទាំសុខភាពនៅក្នុងការថែទាំក្រោមការគ្រប់គ្រង?

### ដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខ

ប្រសិនបើវេជ្ជបណ្ឌិតបានព្យាបាលកូនរបស់អ្នកមិនល្អ ឬខ្ជីខ្ជា ឬអ្នកមិនពេញចិត្តនឹងគុណភាពនៃការថែទាំ ឬអ្នកមិនអាចរកវេជ្ជបណ្ឌិតបានទេ អ្នកអាចដាក់បញ្ជូនពាក្យ **បណ្តឹងសាទុក្ខ** សម្រាប់កូនរបស់អ្នកបាន។ បណ្តឹងសារទុក្ខគឺសម្រាប់ភាពមិនយល់ស្របលើអ្វីដែលបណ្តឹងឧទ្ធរណ៍ ឬសវនាការយុត្តិធម៌ថ្នាក់រដ្ឋមិនគ្របដណ្តប់។ បណ្តឹងសាទុក្ខគឺសម្រាប់បញ្ហា ឬកង្វល់ដែល មិន បដិសេធ ពន្យារពេល កាត់បន្ថយ ឬបញ្ឈប់សេវាកម្មណាមួយរបស់កូនអ្នក។ អ្នកក៏អាចដាក់បណ្តឹងសារទុក្ខទៅកាន់គម្រោងគ្រប់គ្រងការថែទាំរបស់កូនអ្នកផងដែរ សម្រាប់បណ្តឹងទាក់ទងនឹងសេវាកម្មដែលមានការរ៉ាប់រងរបស់កូនអ្នក រួមទាំងគុណភាពនៃការថែទាំ ឬសិទ្ធិទទួលបានការថែទាំផងដែរ។

- អ្នកអាចដាក់ពាក្យបណ្តឹងសាទុក្ខសម្រាប់កូនរបស់អ្នកបានគ្រប់ពេលវេលា។ អ្នកអាចដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខតាមទូរសព្ទ ឬសរសេរតាមឡាញ ឬតាមប្រៃសណីយ៍។ ដើម្បីដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខ ចូរទាក់ទងគម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នក។ សម្រាប់លេខទំនាក់ទំនង ចូរអាន **តារាងទី 1** នៅទំព័រទី 8។
- គម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នកត្រូវតែទទួលស្គាល់បណ្តឹងសាទុក្ខរបស់អ្នកជាលាយលក្ខណ៍អក្សរក្នុងរយៈពេល **5** ថ្ងៃតាមប្រតិទិន គិតចាប់ពីថ្ងៃដែលគម្រោងទទួលបានពាក្យបណ្តឹង។ នេះត្រូវតែរួមបញ្ចូលឈ្មោះ លេខទូរសព្ទ និងអាសយដ្ឋានរបស់បុគ្គលនៅក្នុងគម្រោង ដែលអាចប្រាប់អ្នកបន្ថែមអំពីបណ្តឹងសាទុក្ខរបស់កូនអ្នក និងស្ថានភាពនៃបណ្តឹងនោះ។
- គម្រោងថែទាំក្រោមការគ្រប់គ្រងរបស់កូនអ្នកមានរយៈពេល **30** ថ្ងៃតាមប្រតិទិន ចាប់ពីថ្ងៃដែលអ្នកដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខ ដើម្បីដោះស្រាយបណ្តឹងសាទុក្ខរបស់កូនអ្នក។

## តើអ្នកគួរទាក់ទងទៅអ្នកណាសម្រាប់សំណួរ?

តារាងទី 1

### ទិដ្ឋភាពទូទៅ និងព័ត៌មានទំនាក់ទំនងអំពីប្រព័ន្ធថែទាំក្រោមការគ្រប់គ្រង

**ការថែទាំក្រោមការគ្រប់គ្រងរបស់ Medi-Cal (MCMC)**

កុមារភាគច្រើនទទួលបានសេវាទាំងនេះភាគច្រើនតាមរយៈគម្រោងថែទាំក្រោមការគ្រប់គ្រង៖

- តម្រូវការសុខភាពរាងកាយ ដូចជាការពិនិត្យសុខភាព និងការចាក់ថ្នាំកូន
- តម្រូវការសុខភាពផ្លូវចិត្តដែលមិនមែនឯកទេស ដូចជាការព្យាបាល និងប្រើប្រាស់ឱសថ
- ការសម្របសម្រួលការថែទាំ

ប្រសិនបើកូនរបស់អ្នកមិនទទួលបានសេវាចាំបាច់ ឬមានកង្វល់ណាមួយ ចូរទូរសព្ទទៅគម្រោងថែទាំក្រោមការគ្រប់គ្រងនៃ Medi-Cal របស់កូនអ្នក។ លេខទូរសព្ទរបស់គម្រោងគឺមាននៅលើបណ្ណសម្គាល់នៃគម្រោងរបស់កូនអ្នក។ លេខទូរសព្ទក៏មាននៅលើគេហទំព័ររបស់គម្រោងផងដែរ។ អ្នកក៏អាចស្វែងរកលេខទូរសព្ទរបស់ពួកគេតាមរយៈគេហទំព័រ www.dhcs.ca.gov/mmchpdបានផងដែរ។ ឬ ទូរសព្ទទៅលេខ 916-449-5000។

**សេវាសុខភាពផ្លូវចិត្តឯកទេស (SMHS)**

កុមារមួយចំនួនដែលត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេស ដូចជាការថែទាំស្ថានភាពសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ ទទួលបានការថែទាំនេះតាមរយៈសេវាសុខភាពផ្លូវចិត្តឯកទេស។ ខោនធីនីមួយៗមានគម្រោងសុខភាពផ្លូវចិត្ត។

ប្រសិនបើកូនរបស់អ្នកមិនទទួលបានសេវាចាំបាច់ ឬមានកង្វល់ សូមទូរសព្ទទៅគម្រោងសុខភាពផ្លូវចិត្តប្រចាំខោនធីរបស់កូនអ្នក។ អ្នកអាចស្វែងរកលេខទូរសព្ទតាមរយៈគេហទំព័រ www.dhcs.ca.gov/CMHP។

**ប្រព័ន្ធចែកចាយឱសថដែលរៀបចំដោយ Medi-Cal (DMC-ODS)**

កុមារដែលត្រូវការសេវាព្យាបាលការប្រើប្រាស់សារធាតុញៀន ដូចជាការព្យាបាលការញៀនគ្រឿងញៀន ឬគ្រឿងស្រវឹង រួមទាំងការប្រឹក្សា និងការព្យាបាលតាមគ្លីនិកផ្សេងទៀត ដូចជាការព្យាបាលតាមគេហដ្ឋាននៃការញៀនគ្រឿងញៀន ឬគ្រឿងស្រវឹងសម្រាប់អ្នកជំងឺស្នាក់ព្យាបាល នៅពេលចាំបាច់ ទទួលយកការថែទាំនេះតាមរយៈប្រព័ន្ធចែកចាយឱសថដែលរៀបចំដោយ Medi-Cal។ ខោនធីនីមួយៗមានគម្រោង DMC-ODS ឬស្ថិតនៅក្នុងគម្រោង Drug Medi-Cal។ ដើម្បីស្វែងយល់បន្ថែមអំពី Drug Medi-Cal ចូរអាន **តារាងទី 2** នៅទំព័រទី 11។

ប្រសិនបើកូនរបស់អ្នកមិនទទួលបានសេវាចាំបាច់ ឬមានកង្វល់ សូមទូរសព្ទទៅគម្រោង DMC-ODS របស់កូនអ្នក។ ស្វែងរកលេខទូរសព្ទតាមរយៈគេហទំព័រ www.dhcs.ca.gov/sud-cal។

**ការថែទាំសុខភាពធ្មេញក្រោមការគ្រប់គ្រង (Dental MC)**

កុមារមួយចំនួនដែលរស់នៅក្នុងខោនធី Los Angeles ឬខោនធី Sacramento ទទួលបានសេវាសុខភាពធ្មេញ រួមទាំងការពិនិត្យ និងសម្អាតធ្មេញពីរដងក្នុងមួយឆ្នាំ និងការថែទាំសុខភាពមាត់ធ្មេញ តាមរយៈគម្រោងថែទាំសុខភាពធ្មេញក្រោមការគ្រប់គ្រង។ កុមារដែលរស់នៅក្នុងខោនធីផ្សេងទៀតទាំងអស់ទទួលបានការថែទាំសុខភាពធ្មេញរបស់ពួកគេតាមរយៈថ្លៃឈ្នួលតាមការប្រើប្រាស់សេវាសម្រាប់សុខភាពធ្មេញ (Dental FFS)។ ដើម្បីស្វែងយល់បន្ថែមអំពី Dental FFS ចូរអាន **តារាងទី 2** នៅទំព័រ 11។

ប្រសិនបើអ្នករស់នៅក្នុងខោនធី Los Angeles ឬខោនធី Sacramento ហើយកូនរបស់អ្នកមិនទទួលបានសេវាដែលត្រូវការ ឬមានការកង្វល់ណាមួយ ចូរទូរសព្ទទៅគម្រោង Dental MC របស់កូនអ្នក។ លេខទូរសព្ទគឺមាននៅលើបណ្ណសម្គាល់ Dental MC របស់កូនអ្នក។ លេខទូរសព្ទក៏មាននៅលើគេហទំព័រនៃគម្រោង Dental MC របស់កូនអ្នកផងដែរ។ ឬ ទូរសព្ទទៅលេខ 1-800-322-6384។ អ្នកក៏អាចស្វែងរកលេខទូរសព្ទរបស់គម្រោងតាមរយៈគេហទំព័រ https://bit.ly/DMC-Contactបានផងដែរ។

# តើសិទ្ធិរបស់កូនអ្នកនៅក្នុងថ្លៃឈ្នួលតាមការប្រើប្រាស់សេវារបស់ Medi-Cal មានអ្វីខ្លះ?

ព័ត៌មានខាងក្រោមនៅទំព័រទី 9 -11 អនុវត្តចំពោះថ្លៃឈ្នួលតាមការប្រើប្រាស់សេវា (FFS) របស់ Medi-Cal។ កុមារមួយចំនួនដែលបានចុះឈ្មោះក្នុង Medi-Cal ទទួលបានការថែទាំរបស់ពួកគេតាមរយៈ FFS។ FFS ក៏ត្រូវបានគេហៅផងដែរថាជា Medi-Cal "ធម្មតា"។ កុមារនៅក្នុង FFS ទទួលបានការថែទាំរបស់ពួកគេតាមរយៈ DHCS (ទីភ្នាក់ងារ Medi-Cal របស់រដ្ឋ)។ មិនមានការចូលរួមពីគម្រោងថែទាំក្រោមការគ្រប់គ្រងនោះទេ។ FFS រួមបញ្ចូល Medi-Cal FFS សម្រាប់សេវាសុខភាពផ្លូវកាយ និងសំណុំនៃសេវាសុខភាពផ្លូវចិត្តមានកំណត់ដែលត្រូវបានគេហៅថា "សេវាសុខភាពផ្លូវចិត្តមិនឯកទេស" Drug Medi-Cal សម្រាប់សេវាព្យាបាលការញៀនគ្រឿងញៀន និងគ្រឿងស្រវឹង Dental FFS សម្រាប់ការថែទាំសុខភាពធ្មេញ និង Medi-Cal Rx សម្រាប់ការប្រើប្រាស់ថ្នាំ។ ដើម្បីស្វែងយល់បន្ថែម ចូរអាន **តារាងទី 2** នៅទំព័រទី 11។

ប្រសិនបើកូនរបស់អ្នកមានបញ្ហាក្នុងការទទួលបាន ឬបន្តសេវាកម្មដែលអ្នកគិតថា DHCS គួរតែរ៉ាប់រង ចូរអានចំណុចខាងក្រោម។ ទោះបីជាកូនរបស់អ្នកមិនស្ថិតក្នុងគម្រោងថែទាំក្រោមការគ្រប់គ្រងក៏ដោយ ប្រសិនបើកូនរបស់អ្នកត្រូវការការថែទាំសម្រាប់ស្ថានភាពសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ កូនរបស់អ្នកនឹងទទួលបានការថែទាំនេះតាមរយៈគម្រោងសេវាសុខភាពផ្លូវចិត្តរបស់សេវាសុខភាពផ្លូវចិត្តឯកទេស។ ដើម្បីស្វែងយល់បន្ថែម និងស្វែងរកកន្លែងដែលត្រូវហៅរកជំនួយពីគម្រោងសុខភាពផ្លូវចិត្តរបស់ខោនធី ចូរអាន **តារាងទី 1** នៅទំព័រទី 8។

## តើអ្នកអាចធ្វើអ្វីបាន ប្រសិនបើការថែទាំកូនរបស់អ្នកនៅក្នុង FFS ត្រូវបានពន្យារពេល បដិសេធ កាត់បន្ថយ ឬបញ្ឈប់?

### ស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋរបស់ Medi-Cal

**សវនាការយុត្តិធម៌ថ្នាក់រដ្ឋ** គឺជាឱកាសមួយក្នុងការនិយាយនៅចំពោះមុខចៅក្រម ដើម្បីពិនិត្យមើលសេចក្ដីសម្រេចដោយ DHCS ដែលអ្នកមិនយល់ស្របជាមួយ។ នេះរួមបញ្ចូលទាំងការបដិសេធ ការពន្យារពេល ការកាត់បន្ថយ ឬការបញ្ឈប់នៃសេវាកម្ម។ ចៅក្រមដែលធ្វើការឱ្យក្រសួងសេវាសង្គមកិច្ចនៃរដ្ឋ California មិនមែនជា DHCS នោះទេ។

- បន្ទាប់ពីកូនរបស់អ្នកទទួលបានសេចក្ដីជូនដំណឹងអំពីចំណាត់ការពី DHCS អ្នកអាចស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋ។ អ្នកក៏អាចស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋបានផងដែរ ប្រសិនបើអ្នកមិនទទួលបានសេចក្ដីជូនដំណឹងអំពីចំណាត់ការ។
- អ្នកត្រូវតែស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋក្នុងរយៈពេល **90** ថ្ងៃតាមប្រតិទិន គិតចាប់ពីថ្ងៃដែលអ្នកទទួលបានសេចក្ដីជូនដំណឹងអំពីចំណាត់ការជាលាយលក្ខណ៍អក្សរដោយ DHCS។ ចៅក្រមដែលមិនលំអៀងនឹងពិនិត្យលើករណីរបស់កូនអ្នក។ អ្នកក៏អាចស្នើសុំឱ្យមានសវនាការយុត្តិធម៌ថ្នាក់រដ្ឋបានគ្រប់ពេលផងដែរ ដោយមិនមានសេចក្ដីជូនដំណឹងអំពីចំណាត់ការ។ ប្រសិនបើសេចក្ដីសម្រេចដែលអ្នកបានស្នើសុំឱ្យមានសវនាការនឹងបញ្ឈប់សេវាកម្មដែលកូនរបស់អ្នកទទួលបានរួចហើយ អ្នកអាចស្នើសុំការបន្តនៃអត្ថប្រយោជន៍សម្រាប់កូនរបស់អ្នក។ ចូរអាន **ប្រអប់ទី 5** នៅលើទំព័រនេះ។
- អ្នកអាចស្នើសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋបានតាមរយៈទូរសព្ទ សំបុត្រ ទូរសារ ឬតាមអនឡាញ។ ទូរសព្ទទៅលេខ 1-800-743-8525។ ឬចូលទៅកាន់គេហទំព័រ www.cdss.ca.gov/hearing-requests។

> ប្រអប់ទី 5
>
> ### របៀបស្នើសុំ ការបន្តនៃអត្ថប្រយោជន៍ នៅក្នុងថ្លៃឈ្នួលតាមការប្រើប្រាសសេវា
>
> ប្រសិនបើការជូនដំណឹងនេះនិយាយថាសេវាដែលកូនរបស់អ្នកទទួលបានរួចហើយនឹងបញ្ឈប់ ឬត្រូវបានកាត់បន្ថយ អ្នកក៏អាចស្នើសុំ **ការបន្តនៃអត្ថប្រយោជន៍** (ក៏ហៅផងដែរថា "ការរង់ចាំជំនួយដែលបានបង់") ក្នុងអំឡុងពេលនៃសវនាការយុត្តិធម៌ថ្នាក់រដ្ឋ។
>
> - អ្នកត្រូវតែស្នើសុំសវនាការយុត្តិធម៌ថ្នាក់រដ្ឋ **មុនពេល** សេវាកម្មនេះឈប់ ឬត្រូវបានកាត់បន្ថយ។
> - DHCS ត្រូវតែផ្ដល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកយ៉ាងហោចណាស់រយៈពេល **10** ថ្ងៃតាមប្រតិទិន មុនពេលពួកគេមានគម្រោងបញ្ឈប់ ឬកាត់បន្ថយសេវាកម្មសម្រាប់កូនរបស់អ្នក។

- អ្នកមានសិទ្ធិនាំយកមនុស្សម្នាក់មកតំណាងឱ្យអ្នកនៅក្នុងសវនាការបាន។ អ្នកអាចនាំមិត្តភក្តិ សាច់ញាតិ មេធាវី ឬនរណាម្នាក់ដែលអ្នកជ្រើសរើស។ សម្រាប់ជំនួយផ្លូវច្បាប់ដោយឥតគិតថ្លៃ ចូរអាន **របៀបទទួលបានជំនួយ** នៅទំព័រទី 4។
- អ្នកមិនចាំបាច់បង់ប្រាក់សម្រាប់សវនាការយុត្តិធម៌ថ្នាក់រដ្ឋទេ។ សវនាការយុត្តិធម៌ថ្នាក់រដ្ឋគឺឥតគិតថ្លៃ។
- រដ្ឋមានរយៈពេល **90** ថ្ងៃតាមប្រតិទិនបន្ទាប់ពីកាលបរិច្ឆេទនៃការស្នើសុំឱ្យមានសវនាការយុត្តិធម៌ ថ្នាក់រដ្ឋរបស់កូនអ្នកដើម្បីធ្វើសេចក្តីសម្រេចចុងក្រោយ។ ប្រសិនបើកូនរបស់អ្នកត្រូវការសេវាកម្មភ្លាមៗ ហើយការរង់ចាំរយៈពេល 90 ថ្ងៃនឹងធ្វើឱ្យស្ថានភាពរបស់គេកាន់តែអាក្រក់ទៅ អ្នកអាចស្នើសុំសេចក្តីសម្រេច **រហ័ស** (លឿនជាងនេះ)។ ចូរអាន **ប្រអប់ទី 6** នៅលើទំព័រនេះ។
- សម្រាប់ជំនួយបន្ថែម ចូរអានសេចក្តីជូនដំណឹងដែលកូនរបស់អ្នកទទួលបានពី DHCS។ ឬ ទូរសព្ទទៅលេខ 1-800-743-8525។ ឬ ចូលទៅកាន់គេហទំព័រ www.dhcs.ca.gov/fair-hearing។

ប្រអប់ទី 6

**បណ្តឹងឧទ្ធរណ៍ ឬសវនាការយុត្តិធម៌ថ្នាក់រដ្ឋរហ័ស (លឿនជាងនេះ)**

ប្រសិនបើកូនរបស់អ្នកត្រូវការសវនាការយុត្តិធម៌ថ្នាក់រដ្ឋ **រហ័ស** (លឿនជាងនេះ) ព្រោះតែអាយុជីវិត សុខភាព ឬសមត្ថភាពដំណើរការរបស់កូនអ្នកស្ថិតក្នុងគ្រោះថ្នាក់ ចូរទូរសព្ទទៅលេខ 1-800-743-8525។

## ចុះប្រសិនបើអ្នកមិនសប្បាយចិត្តនឹងការថែទាំរបស់កូនអ្នក វេជ្ជបណ្ឌិត ឬអ្នកផ្តល់សេវាថែទាំសុខភាពនៅក្នុងការថែទាំនៅក្នុង FFS?

### ដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខ

ប្រសិនបើវេជ្ជបណ្ឌិតបានព្យាបាលកូនរបស់អ្នកមិនល្អ ឬខ្ជីខ្ជា ឬអ្នកមិនពេញចិត្តនឹងគុណភាពនៃការថែទាំ ឬអ្នកមិនអាចរកវេជ្ជបណ្ឌិតបានទេ អ្នកអាចដាក់បញ្ជូនពាក្យ **បណ្តឹងសាទុក្ខ** សម្រាប់កូនរបស់អ្នកបាន។ បណ្តឹងសាទុក្ខគឺសម្រាប់ភាពមិនយល់ស្របលើអ្វីដែលសវនាការយុត្តិធម៌ថ្នាក់រដ្ឋមិនគ្របដណ្តប់។ បណ្តឹងសាទុក្ខគឺសម្រាប់បញ្ហា ឬកង្វល់ដែល **មិន** បដិសេធ ពន្យារពេល កាត់បន្ថយ ឬបញ្ឈប់សេវាកម្មណាមួយរបស់កូនអ្នក។

- អ្នកអាចដាក់បញ្ជូនបណ្តឹងសាទុក្ខសម្រាប់កូនរបស់អ្នកសម្រាប់Drug Medi-Cal, Dental FFS ឬ Medi-Cal Rx បានគ្រប់ពេលវេលា។ អ្នកអាចដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខតាមទូរសព្ទ ឬសរសេរតាមឡាញ ឬតាមប្រៃសណីយ៍។ ដើម្បីដាក់បញ្ជូនបណ្តឹងសាទុក្ខ ចូរទាក់ទងទៅ Drug Medi-Cal, Dental FFS ឬ Medi-Cal Rx។ សម្រាប់លេខទំនាក់ទំនង ចូរអាន **តារាងទី 2** នៅទំព័រទី 11។ **មិនមាន** ដំណើរការសាទុក្ខសម្រាប់ Medi-Cal FFS សម្រាប់សេវាសុខភាពរាងកាយ និងសេវាសុខភាពផ្លូវចិត្តដែលមិនមែនឯកទេសនោះទេ។
- DHCS ត្រូវតែទទួលស្គាល់បណ្តឹងសាទុក្ខរបស់អ្នកជាលាយលក្ខណ៍អក្សរក្នុងរយៈពេល **5** ថ្ងៃតាមប្រតិទិន គិតចាប់ពីថ្ងៃដែលគម្រោងទទួលបានពាក្យបណ្តឹង។ វាត្រូវតែរួមបញ្ចូលឈ្មោះ លេខទូរសព្ទ និងអាសយដ្ឋានរបស់បុគ្គលនៅ DHCS ដែលអាចប្រាប់អ្នកបន្ថែមអំពីបណ្តឹងសាទុក្ខរបស់កូនអ្នក និងស្ថានភាពនៃបណ្តឹងនោះ។
- DHCS មានរយៈពេល **30** ថ្ងៃតាមប្រតិទិន ចាប់ពីថ្ងៃដែលអ្នកដាក់បញ្ជូនពាក្យបណ្តឹងសាទុក្ខ ដើម្បីដោះស្រាយបណ្តឹងសាទុក្ខរបស់កូនអ្នកសម្រាប់ Dental FFS និង Medi-Cal Rx។ Drug Medi-Cal មានរយៈពេល **90** ថ្ងៃតាមប្រតិទិនដើម្បីដោះស្រាយបណ្តឹងសាទុក្ខរបស់កូនអ្នក។

## តើអ្នកគួរទាក់ទងទៅអ្នកណាសម្រាប់សំណួរ?

តារាងទី 2

### ទិដ្ឋភាពទូទៅ និងព័ត៌មានទំនាក់ទំនងអំពីថ្លៃឈ្នួលតាមការប្រើប្រាស់សេវា

**ថ្លៃឈ្នួលតាមការប្រើប្រាស់សេវារបស់ Medi-Cal (Medi-Cal FFS)**

កុមារមួយចំនួន ដូចជាកុមារខ្វះលះនៅក្នុងការថែទាំកូនចិញ្ចឹម ទទួលបានសេវាសុខភាពរាងកាយរបស់ពួកគេតាមរយៈ Medi-Cal FFS។

ប្រសិនបើកូនរបស់អ្នកមិនទទួលបានសេវាកម្មទាំងនេះទេ ឬមានការព្រួយបារម្ភ សូមទូរសព្ទទៅលេខ 1-800-541-5555 (TDD 1-800-430-7077)។

**Drug Medi-Cal (DMC)**

កុមារដលែត្រូវការសេវាព្យាបាលការប្រើប្រាស់សារធាតុញៀន ដូចជាការព្យាបាលការញៀនគ្រឿងញៀន ឬគ្រឿងស្រវឹង រួមទាំងការប្រឹក្សា និងការព្យាបាលតាមគ្លីនិកផ្សេងទៀត ដូចជាការព្យាបាលតាមគេហដ្ឋាននៃការញៀនគ្រឿងញៀន ឬគ្រឿងស្រវឹងសម្រាប់អ្នកជំងឺស្នាក់ព្យាបាល នៅពេលចាំបាច់ ទទួលយកការថែទាំនេះតាមរយៈ Drug Medi-Cal។ ខានធីនីមួយៗមានគម្រោង DMC-ODS ឬស្ថិតនៅក្នុងគម្រោង DMC។ ដើម្បីស្វែងយល់បន្ថែមអំពី DMC-ODS ចូរអាន **តារាងទី 1** នៅទំព័រទី 8។

ប្រសិនបើកូនរបស់អ្នកមិនទទួលបានសេវាកម្មទាំងនេះទេ ឬមានការព្រួយបារម្ភ ចូរទូរសព្ទទៅកម្មវិធី DMC របស់កូនអ្នក។ ដើម្បីស្វែងរកលេខទូរសព្ទ សូមចូលទៅកាន់គេហទំព័រ www.dhcs.ca.gov/sud-cal។

**ថ្លៃឈ្នួលតាមការប្រើប្រាស់សេវាសម្រាប់សុខភាពធ្មេញ (Dental FFS)**

កុមារភាគច្រើនទទួលបានសេវាសុខភាពធ្មេញនៃ Medi-Cal របស់ពួកគេតាមរយៈ Dental FFS។ សេវានេះរួមបញ្ចូលទាំងការពិនិត្យ និងសម្អាតធ្មេញពីរដងក្នុងមួយឆ្នាំ និងការថែទាំសុខភាពធ្មេញ។

ប្រសិនបើកូនរបស់អ្នកមិនទទួលបានសេវាទាំងនេះ ឬមានកង្វល់ណាមួយ សូមទូរសព្ទទៅលេខ 1-800-322-6384។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ smilecalifornia.org។

**Medi-Cal Rx**

កុមារទទួលបានសេវាឱសថស្ថាននៃ Medi-Cal របស់ពួកគេតាមរយៈ Medi-Cal Rx។ ទាំងនេះរួមមានឱសថមានវេជ្ជបញ្ជា និងឱសថមិនតម្រូវឱ្យមានវេជ្ជបញ្ជាសម្រាប់អ្នកជំងឺមិនស្នាក់ព្យាបាល ផលិតផលអាហារូបត្ថម្ភបញ្ចូលតាមពោះវៀន ដូចជាបំពង់បញ្ចូលអាហារ និងសម្ភារផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រ។

ប្រសិនបើកូនរបស់អ្នកមិនទទួលបានសេវាកម្មទាំងនេះទេ ឬមានការព្រួយបារម្ភ ចូរទូរសព្ទទៅលេខ 1-800-977-2273។ ស្វែងយល់បន្ថែមតាមរយៈគេហទំព័រ https://bit.ly/3D1rQFV។